**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល**
**(ខេមបូឌា) ភីអិលស៊ី**

*ថ្ងៃ អង្គារ ១៣ កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២៣*

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី ៣៩ អាណត្តិទី២ របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៩:០០ ព្រឹក នៅទីស្នាក់ការក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី ("**ក្រុមហ៊ុន**") ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា តាមរយៈការប្រជុំពីចម្ងាយ (Virtual Meeting) លោក **Yang, Po-Yu** ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី ៣៩ របស់ក្រុមហ៊ុន។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៣៩ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុល លើខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលទទួលបានលទ្ធផល និងអនុម័ត ដូចខាងក្រោម៖

១. លទ្ធផលប្រតិបត្តិការសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៣ និងផែនការសម្រាប់ត្រីមាសបន្ទាប់
២. ការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី ៩ របស់ក្រុមហ៊ុន
៣. ផែនការបែងចែកភាគលាភជូនភាគហ៊ុនិក និងអភិបាលរបស់ក្រុមហ៊ុនសម្រាប់ឆ្នាំ២០២៣
៤. ការបង្កើត និងតែងតាំងសមាជិក សម្រាប់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំង និងលាភការ
៥. កិច្ចពិភាក្សាពីការបន្តអាណត្តិថ្មី ៣ ឆ្នាំ សម្រាប់អភិបាលប្រតិបត្តិ និងមិនប្រតិបត្តិ ចំនួន ៣ រូប
៦. ផែនការនៃការបោះផ្សាយមូលបត្របំណុលដែលអាចបរិវត្តជាមូលបត្រកម្មសិទ្ធិ
៧. ការស្នើសុំអត្តសញ្ញាណវិនិយោគិន និងការបើកគណនីជួញដូរមូលបត្រសម្រាប់ក្រុមហ៊ុន
៨. ការពង្រឹងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន រួមទាំងការបង្កើតគោលនយោបាយនានា
៩. បញ្ហាផ្សេងៗ

អង្គប្រជុំបានបញ្ចប់ទៅនៅវេលាម៉ោង ១១:៣០ ព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសទទួល ខុសត្រូវខ្ពស់ និងឯកភាពគ្នា។

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**

GRAND TWINS INTERNATIONAL (CAMBODIA) PLC.
KINGDOM OF CAMBODIA

ទីស្នាក់ការ: ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:(៨៥៥)២៣ ៨៩០ ៣២៥ /ទូរសារ : (៨៥៥)២៣ ៨៩០ ៣២៦/ គេហទំព័រ : www.Grandtwins.com.kh/ អ៊ីម៉ែល : vuthy.phuong@qmico.com